**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១០៩២ / ១៦-១១-២០១២

**សាលដីកា**

លេខ ៨៩ "ក្រ.III.ច" / ២៥-១១-២០១៣

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ ភ្នំពេញ**

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឲ្យប្រើតាមក្រិត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-១៩៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ១៤-១១-២០១៣ ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជំរះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ១០៩២ ចុះថ្ងៃទី ១៦-១១-២០១២ ដោយមាន៖

**១-ជនជាប់ចោទឈ្មោះ** [redacted] ទិម្ល់ ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតភូមិប្រចក្យ ឃុំព្រៃមូល ស្រុករលៀងឬស្សី ខេត្តកំពង់ឆ្នាំង មានទីលំនៅសព្វ [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) នៅលីវ ទោសពីមុនគ្មាន ។ (ប្តឹងឧទ្ធរណ៍)

-ឃុំខ្លួនតាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៦ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០១២

-មានមេធាវីការពារសិទ្ធិលោក អ៊ុក វ៉ាន់ដេត ។

-ជាប់ចោទពីបទៈ លួចដោយប្រើអំពើហិង្សា ប្រព្រឹត្តនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ ។

## ឯរឿងហេតុមានដូចតទៅៈ

កាលពីថ្ងៃទី ២២-០២-២០១២ ឈ្មោះ [redacted] **ទិមល់** និងបក្សពួកមានឈ្មោះ [redacted] **ស្រីញៀប**, ឈ្មោះ **ស្រីល័ក្ខ** ឈ្មោះ **ទិមុល** និងឈ្មោះ **ទិសាល** ជាមេក្លោង បានមកកាន់ខេត្តកោះកុង ដោយជិះរថយន្តទូរីសមានឈ្មោះ **ទិមុល** ជាអ្នកបើក។ លុះវេលាម៉ោង ១៩:០០នាទី នាថ្ងៃដដែល ពួកគេ បានមកដល់កន្លែងពិពណ៌នៅចំណុចទីលានទាត់បាល់មុខសាលាខេត្តកោះកុងស្ថិតនៅភូមិ ០១សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ពេលនោះឈ្មោះ [redacted] **ទិមល់**,ឈ្មោះ [redacted] **ស្រីញៀប** ,ឈ្មោះ **ស្រីល័ក្ខ** និងឈ្មោះ **ទិសាល** បានធ្វើសកម្មភាពប្រជ្រៀតចូលក្នុងហ្វូងមនុស្ស ដែលកំពុងទិញឥវ៉ាន់ក្នុងស្តង់លក់ឥវ៉ាន់ ដើម្បីលួចលូកហោប៉ៅ និងលួចសម្ភារៈផ្សេងៗ ហើយឈ្មោះ **ទិសាល** បានធ្វើសកម្មភាពយកកូនកន្ត្រៃលួចកាត់ខ្សែក របស់ក្មេងប្រុសម្នាក់ដែលម្តាយកំពុងពរដើរប្រជ្រៀតរកទិញឥវ៉ាន់ ក្រោយពីបានកាត់រួចក៏ប្រគល់ឲ្យទៅឈ្មោះ [redacted] **ទិមល់** រួច ឈ្មោះ [redacted] **ទិមល់** ក៏គេចខ្លួនទៅមាត់សមុទ្រត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខៈ ១១៥ "ច" ចុះថ្ងៃទី ១៩-០៩-២០១២ របស់សាលាដំបូងខេត្តកោះកុង សម្រេចសេចក្តីថា ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] រិមល់ ភេទស្រី អាយុ ២២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៧ (ប្រាំពីរ) ឆ្នាំ ពីបទលួចដោយប្រើអំពើហិង្សា ប្រព្រឹត្តនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០១២ តាមមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-ឱ្យឈ្មោះ [redacted] ស្រីញៀប ភេទស្រី អាយុ ១៣ឆ្នាំ (អនីតិជន) រួចផុតពីការទទួលខុសត្រូវទោសព្រហ្មទណ្ឌ ពីបទលួចដោយប្រើអំពើហិង្សា ប្រព្រឹត្តនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ តាមមាត្រា ៣៥៣,៣៥៧ និងមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ។

៣-វត្ថុតាង

ក-ខ្សែកលោហធាតុពណ៌ទង់ដែក (ខ្សែអង្គាដី) ចំនួនមួយខ្សែ ប្រវែង ៣១ សម ត្រូវប្រគល់ឲ្យទៅម្ចាស់ដើមវិញ។

ខ-ខ្សែកលោហធាតុពណ៌ទង់ដែក (ខ្សែច្រវ៉ាក់ឆាប) ចំនួនមួយខ្សែប្រវែង ៣៥ សម អត្តសញ្ញាប័ណ្ណខ្មែរ ០១សន្លឹក លេខ ០៩០២៥៦៣៣៧ ទូរស័ព្ទដៃម៉ាក Beeline ០១គ្រឿង ,ប្រាក់



Scanned with CamScanner

DOSMIL COLONES ២០០០ ០១សន្លឹក និងកាបូបដៃស្ពាយមួយ ពណ៌ស-សុក្កូឡា ត្រូវប្រគល់ ឲ្យទៅឈ្មោះ វង់ វិមល់ វិញ។

៥-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១០-៩-២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted]វិមល់ មេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ[redacted]ស្រីញៀប និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៩-៩-២០១២ ចំពោះមុខជនជាប់ចោទ [redacted] វិមល់ ,មេធាវីជនជាប់ចោទ កំបាំងមុខជនជាប់ចោទ [redacted] ស្រីញៀប បើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**បាន**ឃើញពាក្យបណ្ដឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] វិមល់ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១១៥ "ច" ចុះថ្ងៃទី ១៩-០៩-២០១២ របស់សាលាដំបូងខេត្តកោះកុង ត្រង់សេចក្ដីសម្រេចទាំងមូល ។

**បាន**ឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

**បាន**ឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

**ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង**

-ជនជាប់ចោទឈ្មោះ [redacted]វិមល់ (អវត្តមាន )

**តំណាងមហាអយ្យការធ្វើសេចក្ដីសន្និដ្ឋាន**

ចម្លើយជនជាប់ចោទបានសារភាពទទួលកំហុសដែលខ្លួនបានប្រព្រឹត្ត ចោទពីបទប្រើអំពើហិង្សា តែពិនិត្យចម្លើយមិនប្រើអំពើហិង្សាទេ មិនបណ្ដាលឱ្យមានគ្រោះថ្នាក់ទេ ការដាក់ទណ្ឌកម្មដល់ទៅ ៧ឆ្នាំហួសហេតុ តាមអគ្គព្រះរាជអាជ្ញារង និងតំណាងមហាអយ្យការសន្និដ្ឋានការដាក់ទណ្ឌកម្ម ៣ឆ្នាំ វាជាការសមស្រប ។ សុំក្រុមប្រឹក្សាជំនុំជំរះពិចារណាតាមច្បាប់ ។

**មេធាវីតំណាងឱ្យដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីសន្និដ្ឋាន**

តុលាការផ្ដន្ទាទោសតាមមាត្រា ៣៥៧ ដោយចោទកូនក្ដីខ្លួនប្រើអំពើហិង្សា តែកូនក្ដីខ្លួនមិនបានប្រើអំពើហិង្សាទេ មិនបណ្ដាលឱ្យគ្រោះថ្នាក់ទេ សុំកែមកមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញ កាលដែលគ្នាប្រព្រឹត្តនោះ គឺគ្រាន់តែយកប្រាក់មិនចិញ្ចឹមអ៊ុំ ស្រី ។

**តុលាការថយទៅពិភាក្សា**

ក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងហើយ។

ក្រោយពីបានស្ដាប់តំណាងមហាអយ្យការធ្វើសន្និដ្ឋាន។

ក្រោយពីបានស្ដាប់មេធាវីធ្វើសេចក្ដីសន្និដ្ឋាន។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ។



Scanned with CamScanner

## សាលាឧទ្ធរណ៍

### យល់ឃើញថា:

១-បណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី ០២.១០.២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ទិមល់ ប្តឹងនិងសាលក្រមព្រហ្មទណ្ឌលេខ ១១៥ "ច" ចុះថ្ងៃទី ១៩-០៩-២០១២ ត្រង់ចំណុចទី១ នៃសាលក្រមរបស់សាលាដំបូងខេត្តកោះកុង ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមអំណានរបស់ជនជាប់ចោទឈ្មោះ [redacted] ទិមល់ បានឆ្លើយទទួលស្គាល់ថាខ្លួនពិតជា បានលួចកាត់ខ្សែកបស់ក្មេងមែន ជាខ្សែកផ្លាទីនត្រូវសមត្ថកិច្ចចាប់ខ្លួនបានភ្លាម និងទទួលស្គាល់ ថាធ្លាប់បានលួចកាត់ខ្សែកនេះពីមុនដែរ ដោយសារជីវភាពក្រីក្រ ទទួលបន្ទុកមើលអ៊ំឈឺនិងប្អូនៗ ព្រោះខ្លួនជាក្មេងកំព្រា សំណូមពរជួយបន្ធូរបន្ថយទោសដល់ខ្លួនផង ។

៣-នាពេលសវនាការសាលាឧទ្ធរណ៍ តំណាងមហាអយ្យការសាលាឧទ្ធរណ៍បានធ្វើសេចក្តីសន្និដ្ឋានសុំឲ្យក្រុមប្រឹក្សាសាលាឧទ្ធរណ៍ពិចារណាឡើងវិញអំពីបទចោទប្រកាន់ គួរតែប្រែមកបទលួចតាមមាត្រា ៣៥៦ វិញ និងគួរបន្ថយទណ្ឌកម្មមក ០៣ឆ្នាំវិញ ជាការសមរម្យ ។

៤-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទក៏បានសន្និដ្ឋានសុំដូចការសន្និដ្ឋានរបស់តំណាងមហាអយ្យការក្នុងការសុំប្តូរមកចោទតាមមាត្រា ៣៥៦ និងបន្ថយទណ្ឌកម្មឲ្យបានសមរម្យ ។

៥-តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាឧទ្ធរណ៍ និងការសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ និងតាមការពិនិត្យលើអង្គហេតុឃើញថាការសន្និដ្ឋាននេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីសាលាឧទ្ធរណ៍ ធ្វើការកែប្រែបទចោទប្រកាន់លើជនជាប់ចោទពីបទលួចដោយប្រើអំពើហិង្សា តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌមកបទលួច តាមមាត្រា ៣៥៦ វិញ និងលើកយកស្ថានសំរាលទោសដល់ជនជាប់ចោទឲ្យបានសមរម្យតាមច្បាប់ ។

៦-សាលក្រមព្រហ្មទណ្ឌលេខ ១១៥ "ច" ចុះថ្ងៃទី១៩.៩.២០១២ របស់សាលាដំបូងខេត្តកោះកុង ដែលបានសម្រេចសេចក្តីត្រឹមត្រូវតាមអង្គហេតុហើយ តែអង្គច្បាប់ គឺការសម្រេចអំពីបទចោទ និងដាក់ទណ្ឌកម្មមិនទាន់ត្រឹមត្រូវតាមច្បាប់ សាលាឧទ្ធរណ៍គប្បីកែប្រែបទចោទឡើងវិញតាមការយល់ឃើញខាងលើ និងលើកស្ថានសំរាលខ្លះដល់ជនជាប់ចោទ ដែលមានការភ្ញាក់រំលឹក នេះជាស្ថានភាពទទួលស្គាល់កំហុស និងដោយមានស្ថានភាពគ្រួសារ ហើយជាក្មេងកំព្រា ដើម្បីឲ្យឆាប់បានចេញមកកសាងខ្លួន រកបរចិញ្ចឹមជីវិតសំរាប់គ្រួសារ ។

### ហេតុដូច្នេះ

### វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី ០២.១០.២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ទិមល់ ទុកជាត្រឹមត្រូវតាមច្បាប់ ។



Scanned with CamScanner

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១១៥ "ច" ចុះថ្ងៃទី ១៩.០៩.២០១២ របស់សាលាដំបូងខេត្តកោះកុង ទុកជាបានការ លើកលែងតែចំណុចទី១ នៃសេចក្តីសម្រេចត្រូវកែប្រែះ

ក-ប្តូរបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ទិមល់ ពីបទលួចដោយប្រើអំពើហិង្សា តាមមាត្រា ៣៥៧ មកបទលួចតាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ

ខ-ផ្តន្ទាទោសលើឈ្មោះ [redacted] ទិមល់ ភេទស្រី អាយុ ២២ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៣ (បីឆ្នាំ) ពីបទអំពើលួច ប្រព្រឹត្តនៅភូមិ ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង កាលពីថ្ងៃទី ២២.០២.២០១២ តាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-សាលដីការនេះជំនុំជំរះនៅថ្ងៃទី ១៤.១១.២០១៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៥.១១.២០១៣ កំបាំងមុខជនជាប់ចោទ ចំពោះមេធាវីការពារជនជាប់ចោទ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។៤

**សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ** |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] . [redacted] | ហត្ថលេខា: [redacted] |

---

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ថ្ងៃទី ១៨ ខែ ៣ ឆ្នាំ២០១៤

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner